# នីតិអន្តរជាតិសាធារណៈ
# PUBLIC INTERNATIONAL LAW

## មេរៀនទី ១២

LECTURE 12

## ការទទួលខុសត្រូវនៃរដ្ឋ

STATE RESPONSIBILITY

# មាតិកា

- កម្មវត្ថុនៃមេរៀន
- ផ្នែកទី១ សេចក្តីផ្តើម
- ផ្នែកទី២ មូលហេតុនៃការទទួលខុសត្រូវ
    - សញ្ញាណទូទៅ
    - ភាពខុសច្បាប់
    - អ្នកទទួលខុសត្រូវ
- ផ្នែកទី៣ ព្យសនកម្ម
    - សញ្ញាណទូទៅ
    - លក្ខខណ្ឌនៃព្យសនកម្ម
    - ការជួសជុលព្យសនកម្ម

# កម្មវត្ថុនៃមេរៀន

នៅក្នុងមេរៀនស្តីពីការទទួលខុសត្រូវនៃរដ្ឋ មានគោលបំណងឲ្យអ្នកសិក្សាបានស្វែងយល់ពី៖

- អ្វីទៅជាការទទួលខុសត្រូវរបស់រដ្ឋ?
- ព្យសនកម្មជាអ្វី?
- សំណងចំពោះព្យសនកម្ម
- លក្ខខណ្ឌសម្រាប់ជួសជុលនូវព្យសនកម្ម
- មូលហេតុដែលនាំឲ្យរួចផុតពីការទទួលខុសត្រូវ

# ផ្នែកទី១ សេចក្ដីផ្ដើម

តាមច្បាប់អន្តរជាតិ គ្រប់ទង្វើរបស់តួអង្គរបស់វា គឺត្រូវមានការទទួលខុសត្រូវ ហើយទង្វើរបស់តួអង្គមួយចំនួនអាចកើតឡើងដោយចេតនា (ចេតនាទុច្ចរិត) និងទង្វើមួយចំនួនទៀតអាចកើតឡើងដោយអចេតនា ឬ អាចកើតឡើងដោយសារមានស្ថានភាពតម្រូវណាមួយ។

# ផ្នែកទី១ សេចក្តីផ្តើម

ព្យសន្តម្ម អាចកើតឡើងដោយអំពើរបស់រដ្ឋ ឬ អង្គការអន្តរជាតិណាមួយ ហើយអ្នកដែលបង្ករនូវព្យសនកម្មនោះត្រូវតែទទួលរ៉ាប់រងក្នុងការជួសជុលនូវព្យសនកម្មនោះ។ នៅក្នុងសតវត្សទី១៩ នីតិស្តីពីការទទួលខុសត្រូវរបស់រដ្ឋបានត្រូវបង្កើតឡើង (នីតិទំនៀមទម្លាប់)។

# ផ្នែកទី១ សេចក្តីផ្តើម

បច្ចុប្បន្ននេះ វិធានស្តីពីការទទួលខុសត្រូវរបស់រដ្ឋ ទោះបីជាពុំទាន់ត្រូវបានចង់ក្រងឲ្យទៅជាវិធានស័ន្ធិញ្ញា ឬ អនុសញ្ញាក៏វាត្រូវបានគេយកមកអនុវត្តយ៉ាងទូលំទូលាយ។ PCIJ នៅក្នុងរឿងក្តី CHORZOW *ជាគោលការណ៍មួយនៃនីតិអន្តរជាតិ ហើយរាល់ការរំលោភបំពាន នាំឲ្យមានព្យសនកម្ម ត្រូវមានការទទួលខុសត្រូវ។*

# ផ្នែកទី១ សេចក្តីផ្តើម

អ្វីដែលនាំឲ្យមានការទទួលខុសត្រូវរបស់រដ្ឋ គឺត្រូវតែមានមូលហេតុច្បាស់លាស់ ជាពិសេសមូលហេតុតាមផ្លូវច្បាប់ (ច្បាប់ជាធរមាន)។ ដើម្បីឲ្យយល់កាន់តែច្បាស់ យើងនឹងធ្វើការសិក្សាពីមូលហេតុទាំងឡាយដែលនាំឲ្យមានការទទួលខុសត្រូវ នៅក្នុងផ្នែកទី២ មូលហេតុនៃការទទួលខុសត្រូវ។

# ផ្នែកទី២ មូលហេតុនៃការទទួលខុសត្រូវ

- សញ្ញាណទូទៅ

ដើម្បីទាមទារឲ្យមានការទទួលខុសត្រូវពីរដ្ឋណាមួយ គេត្រូវធ្វើការពិនិត្យលក្ខខណ្ឌជាច្រើន ថាពិតជានាំឲ្យមានការទទួលខុសត្រូវមែនដែរឬទេ? ហេតុការណ៍ដែលគេលើកយកមកអះអាង ថាពិជាបានបំពានច្បាប់អន្តរជាតិដែរឬទេ?

# ផ្នែកទី២ មូលហេតុនៃការទទួលខុសត្រូវ

- សញ្ញាណទូទៅ

គេត្រូវធ្វើការកត់សម្គាល់ថា តើមានហេតុការណ៍នោះកើតឡើងពិតប្រាកដទេ? កើតចេញពីហេតុការណ៍នោះ នាំឲ្យមានព្យសនកម្មដែរទេ? ហើយតើហេតុការណ៍នោះមានច្បាប់ចែងដែរឬទេ (ខុសច្បាប់)។

# ផ្នែកទី២ មូលហេតុនៃការទទួលខុសត្រូវ

- ភាពខុសច្បាប់

សូមចងចាំថា ហេតុការណ៍ ឬ អំពើនោះ ខុសច្បាប់អន្តរជាតិ ទោះវាមិនខុសទៅនឹងច្បាប់ជាតិក៏ដោយ។ ហើយដែលភាពខុសច្បាប់នៃហេតុការណ៍ ទអំពើទាំងនោះ អាចនាំឲ្យមានការទទួលខុសត្រូវ។

# ផ្នែកទី២ មូលហេតុនៃការទទួលខុសត្រូវ

- ភាពខុសច្បាប់

រឿងក្តី កក័ហ្វ ICJ បានលើកឡើងថា ប្រទេសអាល់បានី ត្រូវទទួលខុសត្រូវចំពោះអំពើដែលខ្លួននៅស្ងៀម មិនបានប្រាប់ឲ្យអង់គ្លេសបានដឹងពីចំការមីន ដែលមានក្នុងដែនសមុទ្ររបស់ខ្លួន ទោះបីជាអាល់បានីមិនមែនជាអ្នកដាក់មីននោះ។

# ផ្នែកទី២ មូលហេតុនៃការទទួលខុសត្រូវ

- ភាពខុសច្បាប់

នៅក្នុងរឿងក្ដីស្ដីពីសកម្មភាពយោធា និងយោធាប្រតិព័ទ្ធនៅក្នុងប្រទេសនីការ៉ាហ្គ័រ ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៨៦ តុលាការ ICJ បានថ្កោលទោសឲ្យសហរដ្ឋអាមេរិកទទួលខុសត្រូវ។

# ផ្នែកទី២ មូលហេតុនៃការទទួលខុសត្រូវ

- ភាពខុសច្បាប់

ការទទួលខុសត្រូវរបស់សហរដ្ឋអាមេរិក ICJ បានលើកឡើងថា ការដាក់មីននៅច្រកចេញចូល នៃកំពង់ផែរប្រទេសនីការ៉ាហ្គ័រ ការហាមមិនឲ្យមានការហោះហើរលើដែនទឹក ជាអាទ៏ គឺជាអំពើខុសច្បាប់ ហើយដែលធ្វើឲ្យប៉ះពាល់ដល់សេរីភាពនៃការធ្វើនាវាចរ និងពាណិជ្ជកម្មតាមផ្លូវសមុទ្ររបស់នីការ៉ាហ្គ័រ។

# ផ្នែកទី២ មូលហេតុនៃការទទួលខុសត្រូវ

- ភាពខុសច្បាប់

ទង្វើរបស់សហរដ្ឋអាមេរិក ត្រូវបានហាមឃាត់ដោយទំនៀមទម្លាប់អន្តរជាតិ នៃការហាមមិនឲ្យប្រើសប្រាស់កងកម្លាំង ការហាមមិនឲ្យធ្វើអន្តរាគមន៍ និងជាពិសេសទៅទៀននោះ គឺការមិនគោរពអធិបតេយ្យរបស់រដ្ឋ។

# ផ្នែកទី២ មូលហេតុនៃការទទួលខុសត្រូវ

- អ្នកទទួលខុសត្រូវ

អ្នកដែលទទួលខុសត្រូវ គឺរដ្ឋទាំងឡាយដែលកិច្ចរបស់គាត់អាចត្រូវអនុវត្តដោយភ្នាក់ងារ ឬ ស្ថាប័នណាមួយរបស់រដ្ឋលើសពីនេះទៀត រដ្ឋក៏ទទួលខុសត្រូវផងដែរចំពោះអំពើនៃផ្នែកដែលពាក់ព័ន្ធផ្សេងទៀតរបស់រដ្ឋ។

# ផ្នែកទី២ មូលហេតុនៃការទទួលខុសត្រូវ

- អ្នកទទួលខុសត្រូវ

ត្រូវចងចាំថា រដ្ឋមិនទទួលខុសត្រូវចំពោះបុគ្គលឯកជនទេ ដែលក្នុងនោះអាចរួមទាំងរូបវន្តបុគ្គល នីតិបុគ្គលឯកជន (ក្រុមហ៊ុនឯកជន)។ លើកលែងតែបានទទួលការព្រមានពីវិសាលភាពនៃអំពើនោះចំពោះរដ្ឋសាមី ហើយរដ្ឋនោះមិនបានចាត់វិធានការទប់ទល់ ឬ រារាំងនូវអំពើនោះ។

# ផ្នែកទី២ មូលហេតុនៃការទទួលខុសត្រូវ

- អ្នកទទួលខុសត្រូវ

រដ្ឋទទួលខុសត្រូវផងដែរលើសកម្មភាពរដ្ឋបាល ដូចជាការចាប់ខ្លួនដោយបំពាន ហើយមានការធ្វើទារុណកម្មយ៉ាងខ្លាំងខ្លា ឬ អាចជាការបណ្តេញចេញពីទឹកដីរបស់ខ្លួនទៅលើជនបរទេស ឬ អាចជាការធ្វើទារុណកម្មអ្នកទោសបរទេស នៅពេលមានសង្គ្រាម ជាអាទិ៍។

# ផ្នែកទី២ មូលហេតុនៃការទទួលខុសត្រូវ

• អ្នកទទួលខុសត្រូវ

ឧទាហរណ៍ ក្នុងរឿងក្ដី រ៉េនបូ វារៀស ដែលបានដោះស្រាយដោយការសម្រុះសម្រួលរបស់អគ្គលេខាធិការ នៃអង្គការសហប្រជាជាតិឆ្នាំ១៩៨៦ ប្រទេសបារាំងបានទទួលស្គាល់នូវការទទួលខុសត្រូវ ចំពោះអំពើរបស់ភ្នាក់ងារសើុបការរបស់ខ្លួន។

# ផ្នែកទី២ មូលហេតុនៃការទទួលខុសត្រូវ

- អ្នកទទួលខុសត្រូវ

ស្រដៀងគ្នានេះផងដែរ ការធ្វើបាបទៅលើអ្នកទោសនៅក្នុងប្រទេសអ៊ីរ៉ាក់នៅឆ្នាំ២០០៤ ដោយឆ្មាំពន្ធនាគាររបស់សហរដ្ឋអាមេរិក និងប្រទេសអង់គ្លេស ក៏ជាសកម្មភាពដែលនាំឲ្យមានការទទួលខុសត្រូវ។

# ផ្នែកទី២ មូលហេតុនៃការទទួលខុសត្រូវ

- អ្នកទទួលខុសត្រូវ

ចំពោះកិច្ចរបស់តុលាការរដ្ឋ ទោះជាគោរពនូវគោលការណ៍ឯករាជ្យយ៉ាងណាក៏ដោយ ដ៏រដ្ឋនូវតែទទួលខុសត្រូវផងដែរ ដូចជាករណីដែលតុលាការផ្តល់ឪកាសឲ្យជនបរទេសចូលខ្លួនទៅក្នុងនីតិវិធីនៃតុលាការរបស់ខ្លួន ជាអាទ៍។

# ផ្នែកទី២ មូលហេតុនៃការទទួលខុសត្រូវ

- អ្នកទទួលខុសត្រូវ

សូមចងចាំថា រដ្ឋមិនមែនសុទ្ធតែត្រូវទទួលខុសត្រូវរាល់គ្រប់អំពើរបស់ខ្លួននោះឡើយ។ ក្នុងកាលៈទេសៈមួយចំនួនរដ្ឋក៏អាចរួចផុតពីការទទួលខុសត្រូវទាំងស្រុង ឬ អាចរួចផុតពិការទទួលខុសត្រូវក្នុងចំណែកណាមួយផងដែរ។

# ផ្នែកទី២ មូលហេតុនៃការទទួលខុសត្រូវ

- អ្នកទទួលខុសត្រូវ

រដ្ឋអាចរួចផុតពីការទទួលខុសត្រូវ ដូចជាករណីអំពើដែលជាកំហុសរបស់ជនរងគ្រោះ ឬ ជាការសមគំនិតរបស់ជនរងគ្រោះក្នុងការប្រព្រឹត្តនូវអំពើ ឬ អាចជាការការពារខ្លួនជាធម្មានុរូប អាចជាករណីប្រធានសក្តិ។

# ផ្នែកទី២ មូលហេតុនៃការទទួលខុសត្រូវ

- អ្នកទទួលខុសត្រូវ

រដ្ឋក៏ទទួលខុសត្រូវផងដែរ ចំពោះសកម្មភាពនៃការបង្កើតច្បាប់ផ្ទៃក្នុង ក្នុងករណីដែលច្បាប់នោះផ្ទុយទៅនឹងការយល់ព្រមរបស់រដ្ឋជាលក្ខណៈអន្តរជាតិ ដូចជាច្បាប់ផ្ទៃក្នុងផ្ទុយនឹងសន្ធិសញ្ញាដែលខ្លួនបានទទួលយក។

# ផ្នែកទី៣ ព្យសនកម្ម

- សញ្ញាណទូទៅ

ព្យសនកម្ម គឺជាធាតុផ្សំមួយយ៉ាងសំខាន់បំផុតសម្រាប់ការទទួលខុសត្រូវរបស់រដ្ឋ ទោះជាគណៈកម្មការច្បាប់អន្តរជាតិរបស់អង្គការសហប្រជាជាតិបានលើកឡើងថា អាចនឹងទទួលខុសត្រូវទោះអំពើនោះមិនបង្កនូវព្យសនកម្ម។

# ផ្នែកទី៣ ព្យសនកម្ម

• សញ្ញាណទូទៅ

ព្យសនកម្ម ជាផលវិបាក ឬ អាចនិយាយថាជាការខូចខាត ឬ ផលប៉ះពាល់ ដែលកើតចេញពីអំពើខុសច្បាប់ ឬ ទោះកើតចេញពីអំពើស្របច្បាប់ក៏ដោយ។ បើតាមវចនានុក្រមខ្មែររបស់សម្ដេចសង្ឃរាជជួន ណាត ព្យសន៍ គឺជាសេចក្ដីវិនាស ដូច្នេះព្យសនកម្ម គឺជាអំពើដែលនាំឲ្យសេចក្ដីវិនាស ខូចខាត ជាអាទិ៍។

# ផ្នែកទី៣ ព្យសនកម្ម

- លក្ខខណ្ឌនៃព្យសនកម្ម

ព្យសនកម្ម ត្រូវតែជាការខូចខាតដែលកើតមានដោយផ្ទាល់ចេញពីអំពើ។ ព្យសនកម្មដោយផ្ទាល់ គឺរដ្ឋជាអ្នករងគ្រោះ ហើយដែលរដ្ឋត្រូវតែបង្ហាញឲ្យឃើញថា មានការពាក់ព័ន្ធគ្នារវាងអំពើ និងការខូចខាតពិតប្រាកដ។

# ផ្នែកទី៣ ព្យសនកម្ម

- លក្ខខណ្ឌនៃព្យសនកម្ម

ព្យសនកម្ម អាចជាព្យសនកម្មផ្នែកសម្ភារៈ ឬជាព្យសនកម្មផ្នែកសីលធម៌ (ព្យសនកម្មផ្លូវចិត្ត)។ ជាទូទៅប្រសិនបើជាព្យសនកម្មជាសម្ភារៈវាងាយស្រួលក្នុងជួសជុលសំណង តែប្រសិនបើជាព្យសនកម្មខាងផ្លូវចិត្តវិញ គឺពិបាកក្នុងវាស់វែងពីទំហំនៃសំណងណាស់។

# ផ្នែកទី៣ ព្យសនកម្ម

- លក្ខខណ្ឌនៃព្យសនកម្ម

ឧទាហរណ៍ ករណីរឿងក្ដីមជ្ឈត្តវិនិច្ឆ័យស្ដីពីការស្នងលោកជួលប្រុន ដែលមានគណកម្មាធិការមជ្ឈត្តករួមបារាំង និងវេណេហ្ស៊ុយអេឡា លោកមជ្ឈត្តករ៉ាល់ស្តុន បានលើកឡើងថា ការខូចខាតខាងផ្នែកមនោសញ្ចេតនាមិនអាចវាស់វែងជាប្រាក់បានទេ។

# ផ្នែកទី៣ ព្យសនកម្ម

- លក្ខខណ្ឌនៃព្យសនកម្ម

លក្ខខណ្ឌអាចទាក់ទងទៅនឹងរដ្ឋរងគ្រោះ ពោលគឺអ្នករងគ្រោះត្រូវតែជាតួអង្គនៃនីតិអន្តរជាតិ តែគេសង្កេតឃើញថាមិនសូវកើតមានឡើយចំពោះអង្គការអន្តរជាតិ។ ដូច្នេះព្យសនកម្មត្រូវកើតឡើងដោយផ្ទាល់។

# ផ្នែកទី៣ ព្យសនកម្ម

- លក្ខខណ្ឌនៃព្យសនកម្ម

ទោះជាយ៉ាងណាក៏ដោយ គេមិនបានទាត់ចោលទាំងស្រុងនូវព្យសនកម្មដែលកើតឡើងចំពោះបុគ្គលទេ។ តែវាគឺជាព្យសនកម្មដែលមិនផ្ទាល់ នេះក៏ព្រោះតែបុគ្គលឯកជនមិនមែនជាប្រធាននៃនីតិអន្តរជាតិនោះឡើយ។

# ផ្នែកទី៣ ព្យសនកម្ម

- លក្ខខណ្ឌនៃព្យសនកម្ម

មូលហេតុដូចបានលើកឡើងខាងលើនេះ ដែលជាហេតុធ្វើឲ្យបុគ្គលឯកជនមិនអាចដាក់ពាក្យប្តឹងដោយផ្ទាល់ប្រឆាំងទៅនឹងរដ្ឋ ឬ អង្គការអន្តរជាតិបានទេ។ ជាហេតុធ្វើឲ្យគាត់ត្រូវពឹងពាក់រដ្ឋរបស់ខ្លួន ឲ្យធ្វើការប្តឹងផ្តល់ជំនួស។

# ផ្នែកទី៣ ព្យសនកម្ម

• ការផ្សះផ្សាព្យសនកម្ម

ជាទូទៅ ការផ្សះផ្សាព្យសនកម្មត្រូវតែធ្វើឲ្យបានសមរម្យ ហើយការផ្សះផ្សាត្រូវមានលក្ខណៈទាំងស្រុង។ ការផ្សះផ្សាអាចត្រូវធ្វើឡើងតាមរបៀបច្រើនយ៉ាង ដែលមានដូចជា ការធ្វើឲ្យដូចដើម ការសងជាទឹកប្រាក់ និងការសងសំណងផ្នែកសីលធម៌ (ការសុំទោស)។

# ផ្នែកទី៣ ព្យសនកម្ម

- ការជួសជុលព្យសនកម្ម
  - ការធ្វើឲ្យដូចដើម៖ ជាការធ្វើឲ្យដូចនូវស្ថានភាពដើម ដែលមើទៅហាក់មិនមានអ្វីបានកើតឡើង ក្នុងទិសដៅលុបបំបាត់នូវផលវិបាកដែលកើតចេញពីអំពើខុសច្បាប់នោះ និងបង្កើតឡើងនូវស្ថានភាព សឹងតែគ្មានរឿងអ្វីកើតឡើង។

# ផ្នែកទី៣ ព្យសនកម្ម

- ការជួសជុលព្យសនកម្ម
  - ការធ្វើឲ្យដូចដើម៖ ការជួសជុលបែបនេះ គឺជាវិធីដែលមានលក្ខណៈល្អប្រសើរជាងគេ។ ប៉ុន្តែការពិតជាក់ស្តែងស្ទើតែមិនអាចទៅរួចទេ ព្រោះថាត្រូវធ្វើយ៉ាងណាដើម្បីឲ្យវាមានស្ថានភាពដូចដើមសុទ្ធសាធ។

# ផ្នែកទី៣ ព្យសនកម្ម

- ការជួសជុលព្យសនកម្ម
  - ការសងជាទឹកប្រាក់៖ នេះជាវិធីក្នុងសងការខូចខាតដែលគេនិយមប្រើ និងមានលក្ខណៈងាយស្រួលផងដែរ។ ការសងជាទឹកប្រាក់ជាវិធីដែលគេច្រើអនុវត្តស័ម្រាប់ព្យសនកម្មមិនផ្ទាល់ ដែលបង្ករឡើងដោយរដ្ឋ។

# ផ្នែកទី៣ ព្យសនកម្ម

- ការជួសជុលព្យសនកម្ម
  - ការសងជាទឹកប្រាក់៖ ព្យសនកម្មផ្ទាល់ អាចត្រូវបានសងជាសម្ភារៈ ឬ ជាសំណងផ្លូវចិត្ត (សំណងផ្នែកសីលធម៌) ឬ អាចសំណងទាំងពីរនេះចូលគ្នាតែម្តងក៏មានដែរ។

# ផ្នែកទី៣ ព្យសនកម្ម

- ការជួសជុលព្យសនកម្ម
  - សំណាងផ្នែកសីលធម៌៖ វិធីនេះក៏អាចជាមធ្យោបាយមួយដែលល្អប្រសើរផងដែរ។ សំណាងបែបនេះអាចនឹងកើតឡើងក្នុងពេលតែមួយ ជាមួយនឹងវិធីទាំងពីរដែលបានលើកឡើងខាងលើ។

# ផ្នែកទី៣ ព្យសនកម្ម

- ការជួសជុលព្យសនកម្ម
  - សំណងផ្នែកសីលធម៌៖ សំណងតាមវិធីនេះ អាចជាការធ្វើការសុំទោសជាសាធារណៈចំពោះអំពើខុសឆ្គងដែលបានកើតឡើង ដូចជាការគោរពទង់ជាតិ ឬ អាចជាការបញ្ជូននូវបេសកជនពិសេសទៅចូលរួមពិធីផ្លូវការណាមួយ ជាអាទិ៍។

# ផ្នែកទី៣ ព្យសនកម្ម

- ការជួសជុលព្យសនកម្ម
  - សំណងផ្នែកសីលធម៌៖ ហើយវាក៏អាចជាការសន្យាមិនឲ្យមានអំពើខុសឆ្គងនោះកើតឡើងសារជាថ្មី ឬ អាចជាការសន្យាធ្វើការថ្កោលទោសបុគ្គលដែលបានប្រព្រឹត្តអំពើ ឬ បុគ្គលទាំងឡាយដែលពាក់ព័ន្ធ ជាអាទ៏។

មេរៀនទី១២ ស្តីពីការទទួលខុសត្រូវនៃរដ្ឋ ត្រូវបានបញ្ចប់។ សូមអរគុណ សម្រាប់ការតាមដានដោយយកចិត្តទុកដាក់ពីសំណាក់អ្នកសិក្សាទាំងឡាយ។